# ព្រះរាជក្រម

នស/រកម/១០០៦/០២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# លក្ខន្តិកៈតំណាងរាស្ត្រ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់នូវអភ័យឯកសិទ្ធិសភា ឋានៈនិងបុព្វសិទ្ធិ វិសមិតភាព និងល័ក្ខខ័ណ្ឌចាំបាច់នានា ដើម្បីធានាជូនតំណាងរាស្ត្របំពេញភារកិច្ចស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

តំណាងរាស្ត្រដែលត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាសកល ក្រោយពីបានប្រកាសសុពលភាព និងស្បថចូលកាន់តំណែងរួចហើយ គឺជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយត្រូវទុកជាមោឃៈ ។

**មាត្រា ៣.-**

តំណាងរាស្ត្រមានអាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលតំណាងរាស្ត្រថ្មីចូលកាន់តំណែង ។

## ជំពូកទី ២
## អភ័យឯកសិទ្ធិសភា

**មាត្រា ៤.-**

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។ អភ័យឯកសិទ្ធិសភា ត្រូវបានចែកចេញជាពីរផ្នែក :

-ការធានាក្នុងការបញ្ចេញយោបល់ ឬ ការបញ្ចេញមតិក្នុងការអនុម័តទាំងឡាយរបស់តំណាងរាស្ត្រ នៅក្នុងក្របខ័ណ្ឌនៃការបំពេញតួនាទីជាតំណាងរាស្ត្រ គឺជាអភ័យឯកសិទ្ធិដាច់ខាតរបស់តំណាងរាស្ត្រ ។

-ការធានាមិនឱ្យមានការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតំណាងរាស្ត្រណាមួយ គឺជាអភ័យឯកសិទ្ធិដោយឡែករបស់តំណាងរាស្ត្រ ។

**មាត្រា ៥.-**

តំណាងរាស្ត្រមិនអាចឆ្លៀតប្រើអភ័យឯកសិទ្ធិសភានេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

**មាត្រា ៦.-**

តំណាងរាស្ត្រត្រូវគោរពបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧.-**

តំណាងរាស្ត្រណាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ នឹងអាចអនុញ្ញាតបើកឱ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន ។

**មាត្រា ៨.-**

សេចក្តីស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្របណាមួយត្រូវធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផងផ្ញើជូនប្រធានរដ្ឋសភា ។

**មាត្រា ៩.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងរយៈពេលសម័យប្រជុំ រដ្ឋសភាត្រូវអនុវត្តនីតិវិធីដូចខាងក្រោមនេះ :

-រដ្ឋសភាអាចប្រជុំជាសម្ងាត់ តាមការស្នើសុំពីប្រធាន ឬ ពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ឬ ពីនាយករដ្ឋមន្ត្រី ។

-កូរ៉ុមប្រជុំលើសពីពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

-ការអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១០.-**

ការលើកអភ័យឯកសិទ្ធិសភាក្នុងចន្លោះសម័យប្រជុំរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវប្រជុំនិងអនុម័តស្របតាមបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ១១.-**

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១២.-**

ក្នុងករណីតំណាងរាស្ត្រណាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ក្រសួងមានសមត្ថកិច្ចអាចចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬ ឃុំខ្លួនបាន ហើយត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នៅចន្លោះសម័យប្រជុំរដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

**មាត្រា ១៣.-**

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ១៤.-**

តំណាងរាស្ត្រដែលអភ័យឯកសិទ្ធិត្រូវបានលើក ហើយស្ថិតក្នុងការចោទប្រកាន់របស់តុលាការ មានសិទ្ធិ និងបុព្វសិទ្ធិដូចតំណាងរាស្ត្រទូទៅ ។

តំណាងរាស្ត្រដែលស្ថិតក្នុងការចាប់ខ្លួន ឬ ឃាត់ខ្លួន ឬ ឃុំខ្លួនជាបណ្តោះអាសន្ន ត្រូវបាត់បង់សិទ្ធិចូលរួមប្រជុំរដ្ឋសភា និងគណៈកម្មការផ្សេងៗ ប៉ុន្តែមានសិទ្ធិទទួលប្រាក់បំណាច់របៀវលែងតែប្រាក់បំណាច់ប្រជុំ ប្រាក់បេសកកម្ម ប្រាក់ប្រេងឥន្ធនៈ ។

តំណាងរាស្ត្រដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថាជាទណ្ឌិត ជាប់ពន្ធនាគារត្រូវបាត់បង់ទាំងស្រុងនូវសិទ្ធិ បុព្វសិទ្ធិ និងសមាជិកភាពជាសមាជិករដ្ឋសភា ។

**មាត្រា ១៥.-**

តំណាងរាស្ត្របណាមួយជាទណ្ឌិត ហើយត្រូវបានព្រះមហាក្សត្រលើកលែងទោស តំណាងរាស្ត្របនោះនឹងបានទទួលសុពលភាព អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិឡើងវិញ ។

**មាត្រា ១៦.-**

តំណាងរាស្ត្រណាដែលមានសាលក្រមស្ថាពរ ឬ សាលដីកាស្ថាពរសម្រេចថា ជាជនគ្មានទោស តំណាងរាស្ត្រនោះត្រូវបានទទួលជាស្វ័យប្រវត្តិនូវអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិពេញលេញឡើងវិញ ។

## ជំពូកទី ៣
## វិសមិតភាព

**មាត្រា ១៧.-**

អាណត្តិនៃតំណាងរាស្ត្រមានវិសមិតភាពជាមួយនឹងមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

**មាត្រា ១៨.-**

តំណាងរាស្ត្រដែលបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល មានឋានៈជាតំណាងរាស្ត្រធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភាឡើយ ។

**មាត្រា ១៩.-**

តំណាងរាស្ត្រក្នុងតំណែងមានវិសមិតភាពជាមួយនឹងមុខងារជាមេធាវីដូចមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

## ជំពូកទី ៤
## ប្រាក់បំណាច់ ឋានៈ និងបុព្វសិទ្ធិ

**មាត្រា ២០.-**

រដ្ឋសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

តំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីជុតលេខនៃព្រះរាជាណាចក្រកម្ពុជា ។

តំណាងរាស្ត្រគ្រប់រូបត្រូវបានទទួលនូវការធានារ៉ាប់រងសង្គមនៅក្នុងអាណត្តិរបស់ខ្លួន ។ ក្នុងករណីដែលតំណាងរាស្ត្រទទួលអនិច្ចកម្មនៅក្នុងអាណត្តិ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងដល់គ្រួសារសពរយៈពេលមួយឆ្នាំទៀត គិតចាប់ពីថ្ងៃទទួលអនិច្ចកម្ម ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបធានាជម្ងឺ របបប្រាក់សោធននិវត្តន៍ របបបេសកកម្ម និងល័ក្ខខ័ណ្ឌធ្វើការងាររបស់តំណាងរាស្ត្រ ។

**មាត្រា ២១.-**

តំណាងរាស្ត្រទទួលប្រាក់សោធននិវត្តន៍ ។

ប្រាក់សោធននិវត្តន៍របស់តំណាងរាស្ត្រ បើកនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

ប្រាក់សោធននិវត្តន៍ បើកបានតែមួយកន្លែងគត់ ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវសម្រេចឱ្យតំណាងរាស្ត្រចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន ។

**មាត្រា ២២.-**

ល័ក្ខខ័ណ្ឌទាំងឡាយដែលអតីតតំណាងរាស្ត្រទទួលបានប្រាក់សោធននិវត្តន៍ :

ក-ជាតំណាងរាស្ត្រគិតចាប់តាំងពីឆ្នាំ ១៩៩៣ មក ។

៍

/ហ/

ខ-មានអាយុចាប់ពី ៦០ (ហុកសិប) ឆ្នាំ ឡើង ។

គ-មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។

**មាត្រា ២៣.-**

រូបមន្តសំរាប់គណនារៀបចំរបបសោធននិវត្តន៍របស់អតីតតំណាងរាស្ត្រ ត្រូវផ្អែកលើប្រាក់បំណាច់តំណាងរាស្ត្រ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង រយៈពេលមួយឆ្នាំរបស់តំណាងរាស្ត្រម្នាក់ៗនៃឆ្នាំចុងក្រោយ កំណត់ស្មើនឹង ១០០% (មួយរយភាគរយ) ។

ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ :

| | |
|---|---|
| -ពី ១ឆ្នាំ ដល់ ៣ឆ្នាំ ទទួលបានសន្ទស្សន៍ | ០,៥ % |
| -លើសពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ទទួលបានសន្ទស្សន៍ | ១ % |
| -ពី ៦ឆ្នាំ ដល់ក្រោម ១១ឆ្នាំ ទទួលបានសន្ទស្សន៍ | ២ % |
| -ពី ១១ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ទទួលបានសន្ទស្សន៍ | ៣ % |
| -ពី ១៦ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ | ៤ % |
| -ចំពោះតំណាងរាស្ត្រក្នុងតំណែងបីអាណត្តិបន្តបន្ទាប់គ្នា ទទួលបានសន្ទស្សន៍ | ៤ % |

អតីតតំណាងរាស្ត្រទទួលប្រាក់សោធននិវត្តន៍ប្រចាំខែរហូតដល់ទទួលមរណភាព វៀរលែងតែត្រូវបានជាប់ឆ្នោតជាតំណាងរាស្ត្រ ។

**មាត្រា ២៤.-**

អតីតតំណាងរាស្ត្រដែលមិនជាប់ឆ្នោតឡើងវិញ ក្រោយពីមានអាយុគ្រប់ ៦០ (ហុកសិប) ឆ្នាំ អាចទទួលបានប្រាក់សោធននិវត្តន៍ ដោយបើកផ្តាច់ត្រឹមរយៈពេលតែមួយឆ្នាំគត់បាន ។

**មាត្រា ២៥.-**

តំណាងរាស្ត្រមានអ្នកជំនួយការមួយចំនួន ដែលជួយធ្វើការងារតាមល័ក្ខខ័ណ្ឌបុគ្គលិកជាប់កិច្ចសន្យា ដែលកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ឯប្រាក់កំរៃជា

110

បន្ទុករបស់ថវិការដ្ឋសភា ។

ដើម្បីមានភាពងាយស្រួលក្នុងការបំពេញការងារ អគ្គលេខាធិការដ្ឋានរដ្ឋសភាជួយដល់តំណាងរាស្ត្រ តាមបែបបទកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ២៦.-**

តំណាងរាស្ត្រក្នុងតំណែងត្រូវទទួលបាននូវ ៖

-ប័ណ្ណសំគាល់អភ័យឯកសិទ្ធិ

-រូបសញ្ញារដ្ឋសភាសំរាប់ពាក់លើអាវ

-រូបសញ្ញាបារមីរបស់រដ្ឋសភា

-ផ្លាករថយន្តរដ្ឋសភា

-លិខិតឆ្លងដែនការទូតផ្ទាល់ខ្លួន សហព័ទ្ធ និងកូនអាយុក្រោម ១៨ឆ្នាំ

-ឯកសណ្ឋានរដ្ឋសភា

-គ្រឿងឥស្សរិយយសពីរជងក្នុងមួយអាណត្តិ

-ការធានារ៉ាប់រងជម្ងឺ នៅក្នុងមន្ទីរពេទ្យរដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយថវិការបស់រដ្ឋសភា ។

**មាត្រា ២៧.-**

មន្ត្រីរាជការស៊ីវិល ឬ កងកំលាំងប្រដាប់អាវុធ ដែលជាប់ឆ្នោតជាតំណាងរាស្ត្រ ត្រូវបានឡើងឋានន្តរសក្តិ ឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពសម្រាប់ទទួលសោធននិវត្តន៍ ។

**មាត្រា ២៨.-**

តំណាងរាស្ត្រក្នុងតំណែងត្រូវបានទទួលងារជា ឯកឧត្តម ឬ លោកជំទាវ ។ អតីតតំណាងរាស្ត្រ ក្រោយពេលដែលបានបញ្ចប់អាណត្តិហើយ ត្រូវបានរក្សាងារជា ឯកឧត្តម អតីតតំណាងរាស្ត្រ ឬ លោកជំទាវអតីតតំណាងរាស្ត្រ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.១០០៦.០៤១

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៤០៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន វិនកេន**